**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៧៦១ ហិកតា នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីព្រៃដែលមានដីកាដកហូត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៨៣ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៧០ ខ.បជ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ **៧៦១ ហិកតា** ក្នុងនោះ (១)ទំហំ **២០៦,៨៦ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង(២)ទំហំ **៥៥៤.០៤ ហិកតា** កាត់ចេញពីដីព្រៃដែលមានដីកាដកហូត (លេខ ១៨៦ ១៩៨ ២១៧ ខបជ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ **៦៩៩,៨៩ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ **៦១,១១ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលក្នុងនោះរួមមាន ៖

- ផ្ទៃដីទំហំ **១១៧,៦៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មទំហំ **១១៤,០៣ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **៣,៦០ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិជោគជ័យ**
- កាត់ផ្ទៃដីសរុបទំហំ **២០៨,៧៨ ហិកតា** ក្នុងនោះ(១) ទំហំ **៨៩,៣៣ ហិកតា** កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង(២)ទំហំ **១១៩,៤៥ ហិកតា** កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ **១៧៩,១១ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **២៩,៦៧ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិព្រៃចាន់**

- ផ្ទៃដីទំហំ **២២០,៧៣ ហិកតា** កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ **២១១,៤០ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **៩,៣៣ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិព្រាវ**
- ផ្ទៃដីទំហំ **១៦៥,៧៦ ហិកតា** កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ **១៥០,៤៣ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **១៥,៣៣ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិសីលាខ្មែរ**
- ផ្ទៃដីទំហំ **៤៨,១០ ហិកតា** កាត់ចេញពីដីគម្របព្រៃដែលមានដីកាដកហូត សម្រាប់ធ្វើប្រទានកម្មទំហំ **៤៤,៩២ ហិកតា** ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង **៣,១៨ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ **នៅភូមិទំនប់ដាច់**

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) (២) (៣) (៤) និង (៥)នៃអនុក្រឹត្យនេះ ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន **២៨៣ គ្រួសារ** ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះរួមមាន ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **២៧ គ្រួសារ** នៅភូមិជោគជ័យ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១៧៨ គ្រួសារ** នៅភូមិព្រៃចាន់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៣២ គ្រួសារ** នៅភូមិព្រាវ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **៣៤ គ្រួសារ** នៅភូមិសីលាខ្មែរ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ **១២ គ្រួសារ** នៅភូមិទំនប់ដាច់ ។

**មាត្រា ៣.**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*